**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខៈ ០០២ សក.សណន

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តជាបណ្តោះអាសន្នសម្រាប់រថយន្តសណ្តោងសីមីរ៉ឺម៉ក ដែលមាន ភ្លៅ៦(ប្រាំមួយ)ឡើង អាចដឹកជញ្ជូនរហូតដល់ទម្ងន់៤៥តោន

យោងលិខិតលេខ១៧៧ សជណ.កបច ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីករណីសំណើសុំគោលការណ៍ពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ឆ្នាំ២០១៤ និងអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ **ក្រសួងសាធារណការ និងដឹកជញ្ជូន** សូមធ្វើការណែនាំ និងដាក់ចេញនូវវិធានការមួយចំនួនសម្រាប់អនុវត្ត ដូចខាងក្រោមៈ

១- អនុញ្ញាតឱ្យម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ឬម្ចាស់រថយន្តធុនធ្ងន់ដែលមានរថយន្តសណ្តោងសីមីរ៉ឺម៉ក ចាប់ពីភ្លៅ៦(ប្រាំមួយ)ឡើងទៅ អាចដឹកជញ្ជូនលើបណ្តាញផ្លូវជាតិ១(មួយ)លេខ និងផ្លូវជាតិ២(ពីរ)លេខ រហូតដល់ **ទម្ងន់៤៥តោន** ចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះតទៅ រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី។

២- ចំពោះរថយន្ត និងរថយន្តសណ្តោងសីមីរ៉ឺម៉កដែលមានភ្លៅតិចជាង ៦(ប្រាំមួយ) ត្រូវបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដដែល។

៣- មន្ត្រីប្រចាំការនៅតាមអង្គភាពស្ថានីយថ្លឹងរថយន្តនីមួយៗ និងមន្ត្រីក្រុមជញ្ជីងចល័ត ត្រូវទទួលបន្ទុកធ្វើការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងត្រូវសម្របសម្រួលលើការអនុញ្ញាតដល់ការដំឡើងកម្រិតទម្ងន់ដូចបានកំណត់ក្នុងចំណុចទី១ខាងលើ ឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងប្រកបដោយស្មារតីមនសិការវិជ្ជាជីវៈដែលមានការទទួលខុសត្រូវខ្ពស់បំផុត ដើម្បីធានាចីរភាពដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ឱ្យបានគង់វង្សតាមអាយុកាលបច្ចេកទេសកំណត់។

៤- សមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា សមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា សមាគមកសិករកម្មកម្ពុជា ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ឬម្ចាស់រថយន្តដឹកជញ្ជូនធុនធ្ងន់គ្រប់ប្រភេទ ត្រូវសហការជាមួយមន្ត្រីអង្គភាពស្ថានីយថ្លឹងរថយន្ត និងមន្ត្រីក្រុមជញ្ជីងចល័តដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យទម្ងន់រថយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅតាមគោលដៅនីមួយៗ ឱ្យមានសង្គតិភាពយ៉ាងត្រឹមត្រូវ និងត្រូវអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៥- ក្នុងករណីដែលមន្ត្រីប្រចាំការនៅតាមអង្គភាពស្ថានីយថ្លឹងរថយន្តនីមួយៗ និងមន្ត្រីក្រុមជញ្ជីងថ្លឹងរថយន្តចល័តណាមួយមិនអនុវត្តតាមសេចក្ដីណែនាំនេះ ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ឬម្ចាស់រថយន្តធុនធ្ងន់ ឬអ្នកបើកបររថយន្តធុនធ្ងន់ អាចជូនដំណឹងមកក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈ ហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន៖ (https://www.facebook.com/ mpwt.gov.kh) ឬទូរស័ព្ទលេខ:១២៧៥។

ប្រភេទរថយន្តសណ្ដោងសឺមីរ៉ឺម៉កដែលមានភ្លៅ៦(ប្រាំមួយ) និងប្រភេទផ្លូវជាតិ១ (មួយ) លេខ និងផ្លូវជាតិ២ (ពីរ)លេខ មានកំណត់បញ្ជាក់លម្អិតក្នុងឧបសម្ព័ន្ធភ្ជាប់នៃសេចក្ដីណែនាំនេះ។

ទទួលបានសេចក្ដីណែនាំនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន សង្ឃឹមយ៉ាងមុតមាំថា សមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា សមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា សមាគមកស្តុភារកម្មកម្ពុជា ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ឬម្ចាស់រថយន្តដឹកជញ្ជូនធុនធ្ងន់គ្រប់ប្រភេទ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ត្រឹមត្រូវ ម៉ឺងម៉ាត់ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ៣រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ប៉េង ពោធិ៍នា**

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋានជំនាញ
- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត
- អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

**គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## តារាងកម្រិតកំណត់ទម្ងន់អតិបរមា និងទម្ងន់កម្រិតអនុគ្រោះមិនលើស ៥% តាមប្រភេទយានយន្តដឹកជញ្ជូន

| ល.រ | ប្រភេទយានយន្តដឹកជញ្ជូន | ទម្ងន់អនុញ្ញាត | ទម្ងន់អនុគ្រោះមិនលើស ៥% |
|---|---|---|---|
| ១ |  | ១៦ តោន | ០.៨ តោន |
| ២ |  | ២១ តោន | ១.០៥ តោន |
| ៣ |  | ២៥ តោន | ១.២៥ តោន |
| ៤ |  | ៣០ តោន | ១.៥ តោន |
| ៥ |  | ៣៥ តោន | ១.៧៥ តោន |
| ៦ |  | ៣៥ តោន | ១.៧៥ តោន |
| ៧ |  | ៣៥ តោន | ១.៧៥ តោន |
| ៨ |  | ៤០ តោន | ២ តោន |
| ៩ |  | ៤០ តោន | ២ តោន |
| ១០ |  | ៤៥ តោន | ២.២៥ តោន |

**ការដាក់ពិន័យចំពោះរថយន្តដែលផ្ទុកលើសចាប់ពី ២០% ឡើងទៅ:**

- ដកបណ្ណបើកបរ ព្យួរទុកចំនួន ២ឆ្នាំ
- ឃាត់យានយន្តទុកចំនួន ១ឆ្នាំ ដោយរក្សាទុកនៅទីតាំងណាមួយសមស្រប ហើយម្ចាស់យានយន្តត្រូវទទួលខុសត្រូវលើការលើកដាក់ទំនិញ និងបង់ថ្លៃឈ្នួលកន្លែងទុកដាក់ថែទាំ យានយន្តដោយខ្លួនឯង
- បញ្ឈប់អាជីវកម្មដឹកជញ្ជូនរបស់ក្រុមហ៊ុនចំនួន ១ឆ្នាំ ក្នុងករណីទទួលរងការពិន័យអន្តរការណ៍រួចម្តងហើយ នៅតែបន្តប្រព្រឹត្តល្មើសទៀត ។

# ឧបសម្ព័ន្ធ ១

## កំណាត់ផ្លូវជាតិកម្រិត១ ចំនួន ០៩ (ប្រាំបួន)ខ្សែ

## ដែលអនុញ្ញាតឱ្យរថយន្តសណ្តោងសីមីរ៉ឺម៉ក ដែលមានភ្លៅ ៦ (ប្រាំមួយ) ឡើង អាចដឹកជញ្ជូនរហូតដល់ទម្ងន់ ៤៥តោនជាបណ្តោះអាសន្ន

| ល.រ | លេខផ្លូវ | ចំណុចផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ គិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| 1 | 1 | ព្រែកឯង (គ.ម ១២+២៧៥) | បាវិត (ព្រំប្រទល់កម្ពុជា វៀតណាម) | 154.575 |
| 2 | 2 | រង្វង់មូលក្បូរស្រូវ (គ.ម ១៩+៣៩៥) | ភ្នំដិន (ព្រំប្រទល់កម្ពុជា វៀតណាម) | 106.375 |
| 3 | 3 | ចោមចៅ (គ.ម ១២+០០០) | វាលរិញ (ផជ៤-គ.ម១៨២+២៨០) | 189.589 |
| 4 | 4 | ចោមចៅ (គ.ម ១២+០០០) | ខេត្តព្រះសីហនុ (កំពង់ផែ) | 214.400 |
| 5 | 5 | គល់ស្ពានព្រែកក្អៅ (គ.ម ១២+២៤០) | ប៉ោយប៉ែត (ព្រំប្រទល់កម្ពុជា ថៃ) | 395.050 |
| 6 | 6 | មហាវិថីឈ្នះឈ្នះ(គ.ម ១២+៧០០) | សិរីសោភ័ណ (បន្ទាយមានជ័យ) | 402.707 |
| 7 | 7 | ស្គន់ (ផជ៦-គ.ម៧៥+០០០) | ត្រពាំងគ្រៀល (ព្រំប្រទល់កម្ពុជា ឡាវ) | 460.830 |
| 8 | 8 | ព្រែកតាមាក់ (ផជ៦-គ.ម ២៤+៣៦០) | ក្រែក (ផជ៧-គ.ម ១៧៩+៥៣០) | 132.356 |
| 9 | 9 | ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង (ផជ៧-គ.ម ៥៩៨) | ភូមិស្លាពរ សង្កាត់ប៉ាល់ហាល់ ក្រុងព្រះវិហារ (ផជ៦២-គ.ម ១៣០) | 143.326 |
| | | ប្រវែងសរុប | | 2 199.208 |

# ឧបសម្ព័ន្ធ ២

## កំណាត់ផ្លូវជាតិកម្រិត២ ចំនួន ៥០ (ហាសិប)ខ្សែ
## ដែលអនុញ្ញាតឱ្យរថយន្តសណ្តោងសីមីរ៉ឺម៉ក ដែលមានភ្លៅ ៦ (ប្រាំមួយ) ឡើង អាចដឹកជញ្ជូនរហូតដល់ទម្ងន់ ៤៥តោនជាបណ្តោះអាសន្ន

| ល.រ | លេខផ្លូវ | ចំណុចផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ គិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| 1 | 11 | អ្នកលឿង (ផជ១-គ.ម ៦១+១៥០) | ថ្នល់ទទឹង (ផជ៧-គ.ម ១៣៦+២៥៤) | 90.280 |
| 2 | 13 | ស្វាយរៀង (ផជ១-គ.ម ១២៦+៥០០) | ភូមិក្របៅ (ផជ៨-គ.ម ១២៣+២៥៦) | 62.400 |
| 3 | 18 | ស្វាយទាប | ព្រៃវល្លិ៍ | 25.660 |
| 4 | 20 | ក្រាំងស្វាយ (ផជ២) | កំពង់ទួល (ផជ៣) | 9.624 |
| 5 | 21 | តាខ្មៅ (ផជ២-គ.ម ១១+០៩០) | ជ្រៃធំ (ព្រំប្រទល់កម្ពុជា វៀតណាម) | 65.562 |
| 6 | 21B | ព្រែកហូរ (ផជ២) | ភូមិតាព្រហ្ម | 12.330 |
| 7 | 22 | អូរចំបក់ (ផជ២-គ.ម ៧៤+០១០) | អង្គតាសោម (ផជ៣-គ.ម ៧៤+៨២០) | 9.615 |
| 8 | 23 | ស្ពានកោះធំ | ពាមរាំង | 19.833 |
| 9 | 31 | បំបែកគូស (ផជ៣-គ.ម ៨១+៩២០) | កំពង់ត្រាច (ផជ៣៣-គ.ម ១៨៣+៨១០) | 54.810 |
| 10 | 31A | ផ្សារឈូក | កំពង់ត្រាច (ផជ៣៣-គ.ម ១៨៣+៨១០) | 30.880 |
| 11 | 33 | ក្រុងកំពត (ផជ៣-គ.ម ១៤៨+១០០) | ប្រែកលក (ព្រំប្រទល់កម្ពុជា វៀតណាម) | 52.270 |
| 12 | 41 | ថ្នល់ទទឹង | ល្អាង (ដងទុង) | 96.450 |
| 13 | 44 | ច្បារមន (ផជ៤-គ.ម ៨៧+៨៧៧) | ឧដុង្គ (ផជ៥) | 140.000 |
| 14 | 45 | កងកេង (ផជ៤-គ.ម ២០៩+១០០) | រាម | 9.300 |
| 15 | 48 | ចំការលួង (ផជ៤-គ.ម ១៤២+៣៥០) | ចាំយាម (ព្រំប្រទល់កម្ពុជា ថៃ) | 161.270 |

| ល.រ | លេខផ្លូវ | ចំណុចផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ គិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| 16 | 48-5 | ចំណោតអូរម្កាក់ | គិរីសាគរ | 60.000 |
| 17 | 50C | កំពង់លែង | ត្រពាំងវែង (ផជ៦) | 32.575 |
| 18 | 51 | ឧដុង្គ (ផជ៥-គ.ម ៣៨+៥៦០) | ថ្នល់ទទឹង (ផជ៤) | 38.010 |
| 19 | 53 | កំពង់ឆ្នាំង (ផជ៥-គ.ម ៩១+០០០) | គោកពេញ | 62.000 |
| 20 | 53A | ឃុំផ្សារ (ផជ៥) | ក្តុល | 29.280 |
| 21 | 53B | ក្រគរ (ផជ៥-គ.ម ១៥៣) | កំរ៉ែង | 22.300 |
| 22 | 55 | ទីរួមខេត្តពោធិ៍សាត់ (ផជ៥-គ.ម ១៨៤+៨៥០) | ថ្មដា (ព្រំប្រទល់កម្ពុជា ថៃ) | 182.166 |
| 23 | 55-4 | វាលវែង | សំឡូត | 66.000 |
| 24 | 56 | បន្ទាយមានជ័យ (ផជ៥-គ.ម ៣៥៩+៧៥០) | ឧត្តរមានជ័យ | 113.620 |
| 25 | 56D | កូប (និមិត្ត) | អូរបីជាន់ | 18.050 |
| 26 | 57 | បាត់ដំបង (ផជ៥-គ.ម ២៩១+០១០) | ព្រំ (ព្រំប្រទល់ថៃ) | 103.340 |
| 27 | 57B | ថ្មគោល (ផជ៥-គ.ម ៣៣១+២៤០) | សំពៅលូន | 90.200 |
| 28 | 57B1 | បវេល ភូមិសាមសិប | ភ្នំព្រឹក | 69.750 |
| 29 | 57B2 | ភូមិសាមសិប កំរៀង | អូរដា | 16.400 |
| 30 | 57-7 | ផ្ញៀវ | ច្រក ៤០០ (ព្រំ-ថៃ) | 55.000 |
| 31 | 58 | អូរជ្រៅ (ផជ៥-គ.ម ៤០៥+៩៩០) | ថ្មដូន | 166.000 |
| 32 | 59 | កូនដំរី (ផជ៥-គ.ម ៣៩២+៨២០) | សំពៅលូន-រថគ្រោះឆេះ (ផជ៥៧) | 140.250 |
| 33 | 60 | សំពងជ័យ (ផជ៦-គ.ម ៩១+៤៣០) | ព្រៃទទឹង (ផជ៧-គ.ម ៩៥+១២០) | 19.990 |
| 34 | 60B | កំពង់ថ្ម | បំបែកខ្លាស្ទុះ | 140.250 |

| ល.រ | លេខផ្លូវ | ចំណុចផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ គិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| 35 | 61 | ថ្នល់កែង ( ផជ៦-គ.ម ៤៦+៥៩០ ) | ព្រែកក្ដាម ( ផជ៥ ) | 15.890 |
| 36 | 62 | ថ្នល់បែក ( ផជ៦-គ.ម ១៧០+៩៥០ ) | ជើងភ្នំ ប្រាសាទព្រះវិហារ | 236.660 |
| 37 | 64 | ដំដែក ( ផជ ៦ ) | ថ្នល់បែក ( ផជ៦២ ) | 112.160 |
| 38 | 67 | ស្វាយធំ ( ផជ ៦ ) | ជាំ ( ព្រំប្រទល់កម្ពុជា ថៃ ) | 133.780 |
| 39 | 68 | ក្រឡាញ់ ( ផជ៦-គ.ម ៣៦៥+៩២៦ ) | អូរស្មាច់ ( ព្រំប្រទល់កម្ពុជា ថៃ ) | 116.860 |
| 40 | 70 | ព្រែទទឹង ( ផជ៧-គ.ម ៩៥+២២០ ) | ពាមជីកង ( កំពង់ចាម ) | 13.530 |
| 41 | 71 | ត្រើង ( ផជ៧-គ.ម ១០៥+៨២២ ) | កំពង់ថ្ម ( ផជ៦-គ.ម ១២៨+២៤០ ) | 57.830 |
| 42 | 71C | ស្រឡប់ | ចំការលើ | 102.718 |
| 43 | 72 | ក្រែក ( ផជ៧-គ.ម ១៧៩+៥៣០ ) | ត្រពាំងថ្លុង ( ព្រំប្រទល់កម្ពុជា វៀតណាម ) | 13.500 |
| 44 | 73 | ប្រធាតុ ( ផជ៧-គ.ម ១៦០+០០០ ) | ក្រុងក្រចេះ | 92.400 |
| 45 | 74 | ស្នួល ( ផជ៧-គ.ម ២៥៤+៩៣០ ) | ត្រពាំងស្រែ ( ព្រំ-វៀតណាម ) | 21.120 |
| 46 | 76 | ស្នួល ( ផជ៧-គ.ម ២៥៤+៩៣០ ) | តាអង្គ ( ផជ៧៨-គ.ម ៥៧៥+០០០ ) | 306.180 |
| 47 | 76-4 | អូរពាន | ដាក់ដាំ ( ព្រំប្រទល់កម្ពុជា វៀតណាម ) | 27.000 |
| 48 | 78 | អូរពងមាន់ ( ផជ៧-គ.ម ៤៥៩+៧០០ ) | អូរយ៉ាដាវ ( ព្រំប្រទល់កម្ពុជា វៀតណាម ) | 191.700 |
| 49 | 88 | ក្របៅ ( ផជ៨-គ.ម ១២២+៨៧០ ) | មុីនជ័យ ( ព្រំប្រទល់កម្ពុជា វៀតណាម ) | 5.630 |
| 50 | 95 | ឆែបមួយ | ភ្នំដែក ( ផជ៦២ ) | 80.760 |
| | | **ប្រវែងសរុប** | | **3 793.183** |

# ឧបសម្ព័ន្ធ ៣

## កំណាត់ខ្សែផ្លូវពិសេស ចំនួន ០៥ (ប្រាំ)ខ្សែ

## ដែលអនុញ្ញាតឱ្យរថយន្តសណ្តោងសឺមីរ៉ឺម៉ក ដែលមានភ្លៅ ៦ (ប្រាំមួយ) ឡើង អាចដឹកជញ្ជូនរហូតដល់ទម្ងន់ ៤៥តោនជាបណ្តោះអាសន្ន

| ល.រ | លេខផ្លូវ | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ គិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| 1 | 146B | ជើងគោ (ផជ ៤-គ.ម ១៧៨+១៦៥) | ស្ទឹងហាវ | 19.000 |
| 2 | 148 | ផ្លូវចូលកំពង់ផែ (ផជ៤) | ស្ទឹងហាវ | 23.000 |
| 3 | 139A | ផ្លូវជាតិលេខ ៣ | ផ្លូវជាតិលេខ ៣៣ | 3.690 |
| 4 | 312 | តាគោក (ផជ១-គ.ម ៧៧+១០០) | បន្ទាយចក្រី (ព្រំប្រទល់កម្ពុជា វៀតណាម) | 28.500 |
| 5 | 319C | ប្រកអន្តរជាតិបាវិត (ផជ១) | ភូមិធ្លក | 9.300 |
| | | **ប្រវែងសរុប** | | **83.490** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការនិងដឹកជញ្ជូន
M.P.W.T
ចូល IN
លេខ ៥៨៤ ស.ក.ខ.ជ
ថ្ងៃទី ០៥.០២.២៤
ម៉ោង ០៩:៣០

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ១៧៧.៧.ឥ.ស.ណ.កបប

ថ្ងៃ អង្គារ ១២រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ឆ្នាំ២០១៤ និងអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

**យោង ៖** - លិខិតលេខ២៤២ សក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ដូចខាងក្រោម៖

- អនុញ្ញាតឱ្យអនុវត្តជាបណ្តោះអាសន្ន ដំឡើងកម្រិតទម្ងន់ពី៤០តោន ទៅដល់៤៥តោន សម្រាប់រថយន្តសណ្តោងសីមីរ៉ឺម៉កចាប់ពីភ្លៅ៦(ប្រាំមួយ)ឡើង ស្របតាមតម្រូវការដឹកជញ្ជូនទំនិញជាក់ស្តែង
- ធ្វើការកែសម្រួលអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ទាំងទម្រង់ ខ្លឹមសារ យន្តការ សមាសភាព និងភារកិច្ចរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ និងស្ថានីយ៍ជញ្ជីងថ្លឹងយានយន្តឡើងវិញ ឱ្យបានសមស្របនឹងស្ថានភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងដើម្បីប្រមូលកម្លាំងគ្នាធ្វើកិច្ចការក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព

- ធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ឬរៀបចំច្បាប់ស្តីពីផ្លូវថ្នល់ឡើងវិញ ដើម្បីកំណត់វិសាលភាពអនុវត្តច្បាប់ ឱ្យសមស្របទៅនឹងបរិបទនៃការរីកចម្រើនរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឆឹយ រឿន**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ